# សេចក្ដីថ្លែងការណ៍របស់ហេង-ពៅ

បកប្រែក្រៅផ្លូវការដោយ លី-ឌៀប
ថ្ងៃទី១៦ សីហា ២០០៦

រហូតមកទល់ថ្ងៃទី២៧ កក្កដា ឆ្នាំ២០០៦, ខ្ញុំជាឧត្ដមសេនីយ៍ទោ អនុរដ្ឋលេខាធិការនៅក្នុងក្រសួងមហាផ្ទៃ និងជាទីប្រឹក្សានាយករដ្ឋមន្ត្រីហ៊ុន-សែន ។ នៅក្នុងពេលជាមួយគ្នានេះ ខ្ញុំបានរក្សាតំណែងរបស់ខ្ញុំជាស្នងការប៉ូលិសក្រុងភ្នំពេញ រហូតមកដល់ខែមករាឆ្នាំ២០០៦ ដែលជាមុខតំណែងរបស់ខ្ញុំតាំងពីឆ្នាំ២០០១មក ។

នៅថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០៦ ពេលខ្ញុំស្ថិតនៅឯបរទេស, នាយករដ្ឋមន្ត្រីរបស់ខ្ញុំបានសុំទៅព្រះមហាក្សត្រសីហមុនី ឲ្យដកខ្ញុំចេញពីតំណែង ហើយព្រះមហាក្សត្រក៏បានឡាយព្រះហត្ថលេខាយល់ព្រមតាម ។

ខ្ញុំឥឡូវនេះកំពុងលាក់ខ្លួននៅក្នុងប្រទេសជិតខាង និងពុំអាចវិលត្រឡប់ទៅកាន់ប្រទេសកម្ពុជាជាទីស្នេហារបស់ខ្ញុំវិញបានឡើយ ។ រដ្ឋាភិបាលរបស់ខ្ញុំបានកំពុងធ្វើការឃោសនាប្រឆាំងខ្ញុំ ចាប់តាំងពីពេលខ្ញុំចាកចេញពីកម្ពុជាកាលពីថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០៦មក ។ ខ្ញុំបានត្រូវបណ្ដាញព័ត៌មានខ្មែរចាត់ទុកថា ជាមនុស្សអាក្រក់ និងជាឧក្រិដ្ឋជន ។ គ្រួសាររបស់ខ្ញុំនៅកម្ពុជា រួមទាំងភរិយាខ្ញុំ ដែលទើបសះស្បើយពីជម្ងឺមហារីក ហើយនិងកូនប្រុសសញ្ជាតិអាមេរិកាំងរបស់ខ្ញុំឈ្មោះ Pov Justin បានត្រូវគេឃុំខ្លួនក្នុងផ្ទះ ។ ពួកគេបានឆែកឆេរផ្ទះទាំងពីររបស់ខ្ញុំ និងរឹបអូសយកទ្រព្យសម្បត្តិរបស់ខ្ញុំ ។ ភាគច្រើននៃបុគ្គលិករបស់ខ្ញុំបានត្រូវគេចាប់ឃុំខ្លួន ពីបទមានមន្ទិលសង្ស័យ ។ ដីកាជាអន្តរជាតិមួយបានចេញ ដើម្បីតាមរកចាប់ខ្លួនខ្ញុំ ។

ខ្ញុំគិតថា នេះជាពេលដែលខ្ញុំត្រូវនិយាយប្រាប់ពិភពលោកឲ្យបានដឹងអំពីរឿងរបស់ខ្ញុំ និងសង្ឃឹមថា ការធ្វើដូច្នេះ ខ្ញុំអាចជំរះខ្លួនខ្ញុំពីឈ្មោះជាប់ប្រឡាក់ប្រឡូសនោះ ។ ខ្ញុំគ្មានអ្វីដូចដែលគេបានចោទប្រកាន់មកលើរូបខ្ញុំនោះទេ ហើយខ្ញុំក៏ពុំដែលបានប្រព្រឹត្តនូវអំពើឧក្រិដ្ឋកម្មអ្វី ដូចដែលគេបានចោទប្រកាន់នោះដែរ ។ ខ្ញុំសូមប្រកាសចំពោះពិភពលោកទាំងមូលថា ខ្ញុំគ្មានទោសកំហុសអ្វីឡើយ ។ ឯកសារនេះគឺជាមធ្យោបាយតែមួយគត់ ដែលខ្ញុំអាចធ្វើទៅបាន ។

ខ្ញុំជឿថា គឺជាការខិតខំប្រឹងប្រែងមិនផ្លាស់ប្ដូររបស់ខ្ញុំ ដើម្បីបំបាត់អំពើពុករលួយពាសវាលពាសកាលនៅកម្ពុជា, ការគាំទ្ររបស់ខ្ញុំដើម្បីធ្វើការផ្លាស់ប្ដូរប្រទេសកម្ពុជាឲ្យប្រែក្លាយទៅជាសង្គមប្រជាធិបតេយ្យ ហើយគោលជំហររបស់ខ្ញុំ គឺប្រឆាំង

និងបែបបទរំលោភសិទ្ធិមនុស្សនៅក្នុងស្រុក ដែលជាហេតុបណ្ដាលឲ្យខ្លួនខ្ញុំធ្លាក់ក្នុងសភាពការណ៍បែបនេះ ។ ខ្ញុំគ្មានស្ដាយក្រោយ ចំពោះអ្វីដែលខ្ញុំបានធ្វើទេ ។ បើខ្ញុំត្រូវស្លាប់ចំពោះជំនឿនិងស្រុករបស់ខ្ញុំ ខ្ញុំបានងើបឈរនិងស្ម័គ្រចិត្តធ្វើយ៉ាងដូ-ច្នេះរួចទៅហើយ ។

ខ្ញុំកើតនៅក្នុងខេត្តកណ្ដាល, ថ្ងៃទី១ ធ្នូ ឆ្នាំ១៩៥៧ ហើយឪពុកម្ដាយរបស់ខ្ញុំទាំងពីរនាក់ជាអ្នកស្រែចំការ ។ ឪពុកម្ដាយរបស់ខ្ញុំបានស្លាប់ចោលខ្ញុំ តាំងពីខ្ញុំមានអាយុ១១ឆ្នាំម្ល៉េះ ។

នៅឆ្នាំ១៩៩២, ពេលខ្ញុំបំពេញការងារជាមន្ត្រីប៉ូលិស នៅក្នុងក្រុមប្រឆាំងឧក្រិដ្ឋកម្មក្រុងភ្នំពេញ, ខ្ញុំបានទទួលរងរបួសដោយត្រូវគេបាញ់ចំជើងខាងឆ្វេង ដែលធ្វើឲ្យខ្ញុំពិការរហូតមកដល់ឥឡូវនេះ ។ ខ្ញុំបាត់បង់ជើងឆ្វេង ដោយសារស្រុករបស់ខ្ញុំ ។

នៅឆ្នាំ១៩៩៥, មានការធ្វើបាតុកម្មពេញពាសក្នុងប្រទេសកម្ពុជា ដឹកនាំដោយ Sene Sane ដើម្បីទាមទារលទ្ធិប្រជាធិបតេយ្យ ។ នាយករដ្ឋមន្ត្រីហ៊ុន-សែនបានចេញបញ្ជាថា បាតុកម្មនោះត្រូវតែកំទេច ។ គាត់បានធ្វើការកោះប្រជុំមួយជាមួយហុក-ឡុងឌី, អគ្គនាយកនៃកម្លាំងប៉ូលិស ។ ខ្លួនខ្ញុំក៏បានត្រូវហុក-ឡុងឌីហៅឲ្យទៅចូលរួមប្រជុំ ក្នុងឋានៈជាមិត្តភក្តិ (ខ្ញុំនៅចាំ Amson An, រដ្ឋលេខាធិការក្រសួងមហាផ្ទៃក៏មានមុខនៅក្នុងប្រជុំដែរ ។ ការប្រជុំធ្វើនៅផ្ទះនាយករដ្ឋមន្ត្រីឯទួលក្រសាំង, ខេត្តកណ្ដាល) ។ នៅពេលនោះ, ខ្ញុំជានាយការិយាល័យប្រឆាំងគ្រឿងញៀននៅភ្នំពេញ ។ នៅពេលប្រជុំ ខ្ញុំបានឮពួកគេនិយាយ ត្រូវធ្វើយ៉ាងណាក៏ដោយ ដើម្បីបញ្ចប់នូវការរំពើតរំពើងក្នុងស្រុកនេះ ។ ខ្ញុំពុំបានដឹងថា គេត្រូវប្រើគ្រាប់បែកដៃទៅលើបាតុករទេ ។ (កកន ៖ យើងជឿថា គឺមេធាវីរបស់លោកហេង-ពៅជាអ្នកសរសេរសេចក្ដីរាយការណ៍ជាភាសាអង់គ្លេសនេះ ។ ឈ្មោះសាមីជនខ្លួនមួយចំនួនសរសេរពុំបានត្រឹមត្រូវដូចជា ៖ Sene Sane ប្រហែលសំដៅ ស៊ិន-ស៊ែន និងឈ្មោះ Amson An ប្រហែលសំដៅ អ៊ំ-សុនអន) ។

គ្រាប់បែកដៃបានសម្លាប់មនុស្សជាង១០នាក់នៅក្នុងវត្ត ។ កូនប្រុសរបស់ Sene Sane បានត្រូវរបួសដោយសារគ្រាប់បែកដៃនោះ រួមទាំងមនុស្ស១០នាក់ផ្សេងទៀត ។ ខ្ញុំពុំបានដឹងថា ពួកគេប្រើគ្រាប់បែកដៃ ប្រឆាំងនឹងបាតុករស្លូតត្រង់អញ្ចើងឡើយ ។ ខ្ញុំគ្មានចំណែកនៅក្នុងរឿងនេះទេ ។ ពេលគ្រាប់បែកផ្ទុះ, ខ្ញុំស្ថិតនៅក្នុងការិយាល័យរបស់ នេត-សាវឿន និយាយគ្នាជាមួយគាត់ អំពីហ៊ុន-សែនជួបជាមួយហុក-ឡុងឌីយ៉ាងដូចម្ដេច ។ ក្រោយនោះ ប៉ូលិសបានត្រូវគេប្រាប់ឲ្យដឹងអំពីការផ្ទុះ ហើយនៅពេលខ្ញុំដឹងនោះ រឿងអាក្រក់បានកើតឡើងរួចទៅហើយ ។ ខ្ញុំគ្រាន់តែបានដឹង នៅក្រោយពេលគ្រាប់បែកផ្ទុះប៉ុណ្ណោះ ។ ប៉ូលិសបានត្រូវគេហៅឲ្យទៅធ្វើការស៊ើបអង្កេត ដើម្បីរកមុខអ្នកទទួលខុសត្រូវការផ្ទុះ ក៏ប៉ុន្តែពួកគេគ្រាន់តែធ្វើការស៊ើបអង្កេតសើៗ ហើយនិងសាកល្បងលាក់ដានជនទទួលខុសត្រូវនោះ ។

នៅក្នុងពេលខ្ញុំកាន់ការនៅការិយាល័យប្រឆាំងគ្រឿងញៀន, ខ្ញុំបានរកឃើញភស្តុតាងបង្ហាញថា គឺមនុស្សរបស់ហ៊ុន-សែនពាក់ព័ន្ធក្នុងអំពើរត់ពន្ធគ្រឿងញៀន ។ ខ្ញុំបានទៅជួបហ៊ុន-សែន ដើម្បីប្រាប់ឲ្យគាត់បានដឹង ។ គាត់បាននាំខ្ញុំទៅបន្ទប់ក្រោមដីផ្ទះរបស់គាត់ ដែលមានការតុបតែងយ៉ាងល្អប្រណិត ។ ហ៊ុន-សែនសួរខ្ញុំ ថាខ្ញុំស្គាល់ឈ្មោះអ្នករត់គ្រឿងញៀននោះឬទេ ។ ខ្ញុំឆ្លើយថា ខ្ញុំស្គាល់ គាត់ឈ្មោះម៉ុង-រិទ្ធី ដែលខ្ញុំជឿថាពិតជាមានការពាក់ព័ន្ធ ។ ខ្ញុំសង្ស័យទៅលើមនុស្សរបស់ហ៊ុន-សែនម្នាក់ទៀត ក៏មានការពាក់ព័ន្ធដែរ តែខ្ញុំមិនប្រាកដ១០០%ទេ ។ ហ៊ុន-សែនគ្មាននិយាយអ្វីទាំងអស់ ។ រួចមកហុក-ឡុងឌី និងហ៊ុយ-ពិសិទ្ធ មេអង្គរក្សហ៊ុន-សែនក៏មកដល់ ធ្វើឲ្យអាក់ខានដល់ការនិយាយគ្នាជាមួយគាត់ ។ ហើយយើងជជែកគ្នាអំពីបាតុកម្មគណបក្សប្រឆាំង ។ ហុក-ឡុងឌីនិយាយទៅកាន់ហ៊ុន-សែនថា «ហេតុអ្វីក៏យើងមិនប្រើគ្រាប់បែកដៃទៅ» ។ ហ៊ុន-សែនឆ្លើយថា ជាគំនិតល្អ... «ខ្ញុំអាចបញ្ជូនសិទ្ធ (ហ៊ុយ-ពិសិទ្ធិ) ឲ្យទៅធ្វើ ហើយគាត់អាចចាត់ការបានល្អណាស់» ។ គាត់ (ហ៊ុន-សែន) បានអនុញ្ញាតឲ្យហុក-ឡុងឌីបើកលុយឲ្យហ៊ុយ-ពិសិទ្ធធ្វើកិច្ចការនេះ ។ ហុក ឡុងឌីបានឆ្លើយថា គាត់នឹងប្រមូលលុយចូលគ្នាឲ្យទៅពួកគេ ។ គាត់ស្នើថាឲ្យខ្ញុំជួបជាមួយសិទ្ធ ។ ក្រោយមកហុក-ឡុងឌីបញ្ជាខ្ញុំទៅរកលុយ (១០០,០០០ដុល្លារអាមេរិក) ឲ្យទៅហ៊ុយ-ពិសិទ្ធ ។ លុយនោះបានមកពីប៉ូលិស ។

នៅថ្ងៃទី៣០ មីនា ១៩៩៧, មេដឹកនាំក្រុមប្រឆាំងសម-រង្ស៊ី បានដឹកនាំបាតុកម្មដើម្បីទាមទារកំណែទម្រង់ប្រព័ន្ធតុលាការនៅកម្ពុជា ។ បាតុកម្មធ្វើនៅខាងមុខមន្ទីររដ្ឋសភា ។ ខ្ញុំស្ថិតនៅជិតវត្តបទុម និងបានឃើញអ្វីដែលកើតឡើង ។ បុគ្គលិករបស់ខ្ញុំ បានដឹកម៉ូតូខ្ញុំ ទៅមើលបាតុកម្មធំនៅខាងក្រៅសភា ។ ២-៤នាទី ក្រោយខ្ញុំទៅដល់, ខ្ញុំបានសូរសម្លេងផ្ទុះយ៉ាងខ្លាំង ហើយមនុស្សស្រែកទ្រហឹងអ៊ឹងអាប់ ។ រួចខ្ញុំបានឃើញមនុស្សបួននាក់ រត់ចេញពីកន្លែងកើតហេតុ ។ ខ្ញុំស្គាល់មនុស្ស២នាក់នៅក្នុងចំណោមពួកគេ ៖ លោកស័ក្តិប្រាំ ផាន់-សារី ហើយនិងលោកមេបញ្ជាការ អ៊ិន-ចំណាន, ទាំងពីរនាក់នេះជាមនុស្សរបស់ហ៊ុន-សែន ។ ខ្ញុំមិនស្គាល់ពីរនាក់ទៀតនោះទេ ។ ពួកគេរត់សំដៅទៅផ្ទះនាយករដ្ឋមន្ត្រី ។ ខ្ញុំបានតាមពួកគេដល់ទីនោះ ដើម្បីចង់ដឹងថា តើពួកគេរត់គេចពីអ្វីមកដែរ ។ ខ្ញុំបាននិយាយជាមួយឧត្តមសេនីយ៍ហ៊ុយ-ពិសិទ្ធ ហើយបានប្រាប់គាត់ថា ខ្ញុំបានឃើញមនុស្សបួននាក់រត់ចេញពីកន្លែងកើតហេតុ ហើយនិយាយថាពួកគេមិនត្រូវបោះគ្រាប់បែកដៃអញ្ចឹងទេ ។ គាត់ប្រាប់ខ្ញុំលាក់ឲ្យស្ងាត់ មិនឲ្យនិយាយប្រាប់អ្នកណាទាំងអស់ ។ ក៏ប៉ុន្តែខ្ញុំខឹងនិងរកាំក្នុងចិត្ត ។ ខ្ញុំត្រូវតែនិយាយប្រាប់អ្នកណាមួយអំពីរឿងនេះ ។ ខ្ញុំទៅជួបហុក-ឡុងឌី ដែលខ្ញុំចាត់ទុកក្នុងពេលនោះជាមិត្តភក្តិ ។ ខ្ញុំមានអារម្មណ៍ថា ខ្ញុំបានរាយការណ៍ទៅហុក ហើយមិនយល់សោះថា តើហេតុអ្វីបានជាហ៊ុន-សែនជ្រើសរើសសម្លាប់មនុស្សច្រើនដូច្នេះ ។ ក៏ប៉ុន្តែគាត់ប្រាប់ខ្ញុំដដែល ឲ្យរក្សាការស្ងាត់ស្ងៀម និងមិនត្រូវនិយាយ

ប្រាប់ទៅនរណាអំពីរឿងនេះឡើយ ។ នៅក្នុងចំណោមមនុស្សដែលស្លាប់និងរបួសនោះ មានជនជាតិអាមេរិកាំងម្នាក់ ។ ខ្ញុំយល់ថា រដ្ឋាភិបាលអាមេរិកាំងបានបញ្ជូនមនុស្សរបស់គេមកស្រុកខ្មែរដើម្បីស៊ើបអង្កេត ។

នៅឆ្នាំ២០០៣, ផាន់-សារីបានមកជួបខ្ញុំនៅក្នុងការិយាល័យ ។ គាត់បានសារភាពចំពោះខ្ញុំថា គាត់ជាជនដែលបានបោះគ្រាប់បែកដៃនោះ ។ គាត់និយាយថា គាត់ក្រៀមក្រំយ៉ាងខ្លាំង ពីព្រោះគាត់បានសម្លាប់មនុស្សជាច្រើន ។ គាត់រអ៊ូថា ហ៊ុន-សែនធ្លាប់ប្រើគាត់ឲ្យធ្វើកិច្ចបានសំរេច ។ ពេលគាត់មានបញ្ហា គ្មាននរណារវល់ជួយគាត់ទេ ។ គាត់និយាយថា គាត់ធ្វើនេះពីព្រោះហ៊ុន-សែនបញ្ជាគាត់ឲ្យធ្វើ ហើយគាត់ត្រូវតែបំពេញចិត្តហ៊ុន-សែន ។ គាត់បានទទួលស្គាល់ថា គាត់បានសម្លាប់មនុស្សច្រើនណាស់ពីមុនមក ។ គាត់និយាយថា គាត់ឥឡូវនេះសូម្បីតែលុយក៏គ្មានចិញ្ចឹមកូនផង ។ ខ្ញុំបានថតទុកសម្លេងការសន្ទនាគ្នានេះ ។

★ ការរឹបអូសកញ្ឆាចំនួន៧តោន ៖

នៅឆ្នាំ១៩៩៧, ខ្ញុំជានាយការិយាល័យប្រឆាំងគ្រឿងញៀន ។ ខ្ញុំរឹបអូសយកបានកញ្ឆាចំនួនប្រាំពីរតោន ជារបស់ក្រុមហ៊ុនម៉ុង-រិទ្ធី ។ ម៉ុង-រិទ្ធី ជាមិត្តជិតស្និទ្ធរបស់ហ៊ុន-សែន ។ កញ្ឆាលាក់នៅក្នុងកុងថេន័រពីរ និងរៀបចំរួចស្រេចសំរាប់ដឹកបញ្ជូនទៅកាន់ប្រទេសន័កវេ ។ ការចាប់កើតឡើងនៅកំពង់ផែក្រុងសីហនុ ។ ក្រោយពេលចាប់, លោកហូ-សុខ អនុរដ្ឋលេខាធិការក្រសួងមហាផ្ទៃមកពីគណបក្សហ៊្វុនស៊ិនប៉ិច បានសុំខ្ញុំឲ្យចាប់ឃុំខ្លួនម៉ុង-រិទ្ធី ។ ខ្ញុំពុំអាចធ្វើបានទេ ដោយសារម៉ុង-រិទ្ធីជាក្លឹម្រាក់របស់ហ៊ុន-សែន ហើយគាត់មុខតែធ្វើអន្តរាគមន៍ ។ ហ៊ុន-សែនគាត់បានប្រកាសតាមវិទ្យុនិងទូរទស្សន៍ថា បើម៉ុង-រិទ្ធីត្រូវចាប់ឃុំខ្លួន ខ្លួនគាត់នឹងធ្វើឲ្យប្រាកដថា គ្មាននរណាប៉ះពាល់ខ្លួនម៉ុង-រិទ្ធីបានឡើយ ។ ដល់ដូច្នេះទៅ ខ្ញុំពុំអាចធ្វើអ្វីបានទេអំពីរឿងនេះ ។ ក្រោយមក, ស្ថានទូតកាណាដាបានអញ្ជើញខ្ញុំឲ្យទៅប្រទេសកាណាដា ដើម្បីនិយាយត្រួសៗប្រាប់រដ្ឋាភិបាលកាណាដាអំពីការចាប់បាននេះ ។ ហ៊ុន-សែនខឹងនឹងហូ-សុខយ៉ាងខ្លាំង ។ មុនពេលខ្ញុំត្រូវចាកចេញទៅប្រទេសកាណាដា, ហ៊ុន-សែនបានហៅខ្ញុំទៅផ្ទះរបស់គាត់ ហើយបានសុំឲ្យខ្ញុំកុំទៅប្រទេសកាណាដាអី ។ គាត់សុំឲ្យខ្ញុំប្រាប់ទៅកាណាដាថា ខ្ញុំជាប់រវល់ពុំអាចទទួលការអញ្ជើញបានទេ ។ រឿងចាប់កញ្ឆា ក៏បានក្លាយទៅជារឿងធំខុសធម្មតា ពីព្រោះមានការពាក់ព័ន្ធជាមួយមនុស្សរបស់ហ៊ុន-សែន ។ ហ៊ុន-សែនបានចេញមុខការពារម៉ុង-រិទ្ធីយ៉ាងចំហ ។ ហ៊ុន-សែននិយាយថា បើខ្ញុំនិយាយរឿងចាប់បានគ្រឿងញៀននេះទៅកាណាដា សហគមន៍អន្តរជាតិមុខតែគាបសង្កត់មកលើរដ្ឋាភិបាលខ្មែរ ។ គាត់ស្នើថា ឲ្យខ្ញុំស្ងប់ស្ងាត់ទៅ ។ បើខ្ញុំធ្វើតាមដូចដែលគាត់និយាយប្រាប់ ម៉ុង-រិទ្ធីនឹងឲ្យឡានថ្មីមកខ្ញុំមួយគ្រឿង ។ បន្ទាប់មក ម៉ុង-រិទ្ធីក៏បានមកជួបខ្ញុំជាមួយនាយករដ្ឋមន្ត្រី ។ ហ៊ុន-សែនក៏បានសុំខ្ញុំផងដែរ ឲ្យធ្វើសន្និសិទកាសែតមួយ បដិសេធពុំមានការចាប់

អ្វីកើតឡើងទេ និងឲ្យលាក់បំបាំង ។

ខ្ញុំខ្លាចហ៊ុន-សែន ហើយគាត់មានអំណាចខ្លាំងណាស់ ។ ខ្ញុំគ្មានការជ្រើសរើ-សទេ ក្រៅពីស្តាប់តាមបង្គាប់ ។ ខ្ញុំបានទទួលឡានមួយគ្រឿងពីម៉ុង-រិទ្ធី គឺជាឡាន 1997 Landcruiser Toyota ។ ការិយាល័យខ្ញុំបានត្រូវផ្តល់ឲ្យនូវឡាន Hilux ជំនុំមួយ ក្រៅសំរាប់ប្រើប្រាស់ ដែលមានឃីហោម៉ុង-រិទ្ធីនៅពីលើនោះ ។ ក្រោយបន្ទាប់មក ហ៊ុន-សែនបានបញ្ជាឲ្យខ្ញុំ ទៅចាប់ឃុំខ្លួនមនុស្សម្នាក់ផ្សេងទៀតឈ្មោះ ឆាយ-សុខុម ជំនួសវិញ ។ ឆាយ ធ្វើការជាបេអ៊ីម មកពីគណបក្សហ៊្វុនស៊ិនប៉ិច ។

★ <u>ការធ្វើឃាតទៅលើហូ-សុខ</u> ៖

បន្តិចក្រោយឧប្បតិហេតុខាងលើនេះ, ក៏មានអំពើរដ្ឋប្រហារខែកក្កដាឆ្នាំ១៩៩៧ ដឹកនាំដោយហ៊ុន-សែន ដើម្បីកំចាត់គណបក្សហ៊្វុនស៊ិនប៉ិច ។ លោកហូ-សុខបាន ទៅស្ថានទូតសឹង្ហបូរីនៅភ្នំពេញ ដើម្បីសុំជ្រកកោន ពីព្រោះហ៊ុន-សែននិងហុក-ឡុងឌីកំពុងសាកល្បងតាមចាប់ខ្លួនគាត់ ដែលគាត់មកពីគណបក្សហ៊្វុនស៊ិនប៉ិច ។ ការសុំជ្រកកោនបានបដិសេធ ហើយហូ-សុខត្រូវគេបណ្តេញចេញ ។ ហុក-ឡុងឌី ក៏ចាប់គាត់បាន រួចបញ្ជាឲ្យអង្គរក្សនាំយកទៅការិយាល័យរបស់ឧត្តមសេនីយ៍ម៉ា-សឿនខាងគណបក្សប្រជាជន ។ ហុក-ឡុងឌីបានចេញបញ្ជាផ្ទាល់មកខ្ញុំ ឲ្យទៅនាំហូ-សុខទៅកាន់ការិយាល័យខ្ញុំ ។ ពេលខ្ញុំទៅដល់ទីនោះ មានមនុស្ស៦នាក់ប្រដាប់ដោយអាវុធ ដែលហុក-ឡុងឌីបានបញ្ជូនមក រង់ចាំខ្ញុំរួចជាស្រេច ។ ខ្ញុំស្គាល់មនុ-ស្ស២នាក់នៅក្នុងចំណោមនោះ គឺកែវ-វិចិត្រ និងប៊ុនណា ។ ពួកគេបាញ់ហូ-សុខ នៅខាងក្រៅការិយាល័យម៉ា-សឿន ។ ខ្ញុំសួរពួកគេអំពីការបាញ់សម្លាប់ ។ ប៊ុនណា ឆ្លើយថា ហុក-ឡុងឌីបញ្ជូនឲ្យពួកគេមកសម្លាប់ហូ-សុខ ។ ហុក-ឡុងឌីមិនចូលចិត្តហូ-សុខទេ ។ ខ្ញុំភ្ញាក់ផ្អើលខ្លាំងណាស់ ហើយទូរស័ព្ទទៅហុក-ឡុងឌី ។ ហុក-ឡុងឌីនិយាយថា បើហូ-សុខនៅរស់ គាត់បង្កើតបញ្ហាដល់យើងច្រើនណាស់ ។ គាត់សុំខ្ញុំឲ្យទៅប៊ុនណា នូវឡានមួយគ្រឿងស្រាក់ត្តាពីប៉ូលិស ដើម្បីជារង្វាន់ ។ ខ្ញុំក៏ធ្វើតាមដូចគាត់ប្រាប់ ហើយឲ្យទៅប៊ុនណានូវឡាន Camry 97 មួយគ្រឿង ។

មានមនុស្សទាំងអស់ប្រាំនាក់ ជាសាក្សីនៃការសម្លាប់នេះ ៖ ម៉ា-សឿន, ធន-អ៊ឹម និងបីនាក់ផ្សេងទៀតដែលរួមមាន ឧត្តមសេនីយ៍ ធន-លឹម, ស័ក្តិប្រាំ អ៊ិន-បូរ៉ា, ស័ក្តិប្រាំសូ-វណ្ណា ហើយនិងកងប្រឆាំងឧក្រិដ្ឋកម្មដទៃទៀត ។

★ <u>ការស្លាប់នៃតារាភាពយន្ត ពិសិដ្ឋ-ពិលិកា</u> ៖

នៅឆ្នាំ១៩៩៩, ខ្ញុំជាមេការិយាល័យប្រឆាំងឧក្រិដ្ឋកម្ម ជានាយករង និងជាអ្នកទទួលបន្ទុកស៊ើបអង្កេតការស្លាប់នៃតារាភាពយន្ត ។ ខ្ញុំបានរកឃើញថា មុនពេលនាងស្លាប់ នាងបានសាហាយជាមួយហុក-ឡុងឌី ។ ប្តីរបស់នាងបានចេញទៅបរទេសញឹកញាប់ ទុកចោលនាងម្នាក់ឯងនៅស្រុកខ្មែរ ។ ហុក-ឡុងឌីតែងទៅរកជួបនាងជាញឹកញាប់ ហើយយកនាងទៅរាំកំសាន្ត និងទិញជំនួនឲ្យនាងជាដើម...។ នៅ

ក្នុងពេលទំនាក់ទំនងគ្នានោះ នាងមានកូនប្រុសមួយជាមួយហុក-ឡុងឌី ។ រួចបន្ទាប់មកហុក-ឡុងឌីបាននាំយកទៅបង្ហាញហ៊ុន-សែន ។ ហ៊ុន-សែនក៏បានជួបនាង។ មុនពេលជួបហ៊ុន-សែន នាងមិនសូវមានលុយកាក់ទេ ។ ក៏ប៉ុន្តែក្រោយមក នាងមានលុយយ៉ាងច្រើន ។ នៅក្នុងកុងធនាគារកាណាដា បង្ហាញលុយទាំងអស់ចំនួន ៣0,000 ដុល្លារអាមេរិក នៅពេលនាងស្លាប់ ។ នាងបានទទួលឡានថ្មីម៉ាក Honda CRV ហើយនិងវីឡាមួយ ។ នាងមានការព្រួយបារម្ភចំពោះសន្តិសុខផ្ទាល់ខ្លួនរាល់ថ្ងៃ ដោយសារប្រពន្ធរបស់ហ៊ុន-សែនដឹងអំពីទំនាក់ទំនងសម្ងាត់នេះ ។ ប្រពន្ធហ៊ុនសែនស្តីបន្ទោសហុក-ឡុងឌី ជាអ្នកដឹកញ៉ើបនរីឈ្មោល ។ ហុក-ឡុងឌីក៏សំរួលជាមួយប្រពន្ធហ៊ុន-សែន ដោយសន្យាថា នឹងសាកល្បងបំបែកតារាភាពយន្តចេញពីហ៊ុន-សែន ។ ក្នុងមួយរំពេចនោះ ស្រាប់តែតារាភាពយន្តត្រូវគេសម្លាប់ ។ ខ្ញុំបានរកឃើញថា ឃាតករនោះគឺជាអង្គរក្សម្នាក់របស់ហុក-ឡុងឌី ។ ខ្ញុំបានទៅសាកសួរប៉ុនណា ហើយវាបានសារភាពថា វាមានការពាក់ព័ន្ធជាមួយនិង កែវ-វេត ក្នុងការសម្លាប់នេះ ក្រោមបញ្ជារបស់ហុក-ឡុងឌី ។

ដោយសារអំពើឧក្រិដ្ឋកម្មពាក់ព័ន្ធនឹងហុក-ឡុងឌី, ខ្ញុំពុំអាចធ្វើអ្វីបានទាំងអស់ក្នុងរឿងនេះ ។ ខ្ញុំពុំអាចធ្វើការចាប់ខ្លួនបានទេ ។ ខ្ញុំមានការរកាំក្នុងចិត្តយ៉ាងខ្លាំង ដោយសារមនុស្សស្លូតត្រង់ម្នាក់ត្រូវគេសម្លាប់ ហើយខ្លួនខ្ញុំជាប៉ូលីសមិនអាចធ្វើអ្វីបានទាល់តែសោះនោះ ។

(មានតនៅលេខក្រោយ)